# កម្រងឯកសារអំពី

## ក្សេត្របរិស្ថានដំណាំស្រូវក្នុងប្រទេសកម្ពុជា
## ការកំណត់ក្រុមដីស្រែ
## លក្ខណៈសំខាន់ៗរបស់ពូជស្រូវចំនួន ១០ ពូជ
## វិធីសាស្ត្រសម្រិតសម្រាំងគ្រាប់ពូជស្រូវ



Cambodian Agricultural Research and Development Institute (CARDI)

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានត្រូវបង្កើតឡើង ដោយអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៩ ដោយរាជរដ្ឋាភិបាលកម្ពុជា ជាគ្រឹះស្ថានសាធារណៈ មានលក្ខណៈរដ្ឋបាល ក្នុងគោលបំណងលើកស្ទួយកម្រិតជីវភាពរបស់ប្រជាកសិករកម្ពុជា តាមរយៈការអភិវឌ្ឍបច្ចេកវិទ្យាសមស្របដើម្បីបង្កើនផលិតភាពកសិកម្ម ក្រោមទស្សនទាន " បច្ចេកវិទ្យាដើម្បីវិបុលភាពសង្គម " ។

រក្សាសិទ្ធិ , ២០១១

ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

ប្រអប់សំបុត្រលេខ ០១ , ភ្នំពេញ , កម្ពុជា

ផ្លូវជាតិលេខ ០៣ សង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: ៨៥៥-០២៣ ៦៩១៩ ៦៩៣\៥

ទូរអក្ខរ: cardi@cardi.org.kh

គេហទំព័រ: www.cardi.org.kh

បោះពុម្ពលើកទី១, ឆ្នាំ ២០១១

ចំនួន ៣៨០០០ ច្បាប់

ឧបត្ថមថវិកាសម្រាប់បោះពុម្ពដោយ Cambodia Agricultural Value Chain Program (CAVAC)

Australian Center for International Agricultural Research (ACIAR)

Cambodian Agricultural Research and Development Institute (CARDI)

# អារម្ភកថា

ឆ្នាំ ១៩៩៥ ជាឆ្នាំដែលប្រទេសកម្ពុជាផលិតស្រូវបានគ្រប់សេចក្តីត្រូវការក្នុងស្រុក និងមានអតិរេកប្រមាណ ៥ សែនតោន បន្ទាប់ពីកសាងប្រទេសចេញពីរបបកម្ពុជាប្រជាធិបតេយ្យ អស់រយៈពេល ១៥ ឆ្នាំ។ ចាប់ពីពេលនោះមក អតិរេកស្រូវបានកើនកាន់តែច្រើនឡើងៗរហូតដល់ប្រមាណ ៣,៧ លានតោនសម្រាប់ឆ្នាំ ២០១១ ជាមួយនឹងការកើនទិន្នផលពី ១,៦៥ ត/ហត នាឆ្នាំ១៩៩៥ទៅ២,៩២ ត/ហត នាឆ្នាំ២០១០។

យោងតាមកំណើនអតិរេកនេះ និងស្របតាមតម្រូវការអង្ករក្នុងពិភពលោកកាន់តែកើនឡើងជាលំដាប់ កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០ **រាជរដ្ឋាភិបាលកម្ពុជា** បានប្រកាសដាក់ឲ្យប្រើប្រាស់នូវ **ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ** ក្នុងគោលបំណងប្រែក្លាយអង្ករឲ្យទៅជា មាស ស ពិតប្រាកដរបស់ប្រជាជនកម្ពុជា។ អនុវត្តតាម **ឯកសារគោលនយោបាយ** នេះ និងដោយមានការឯកភាពពី **រាជរដ្ឋាភិបាល** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្សព្វផ្សាយ និងជំរុញឲ្យកសិករប្រើប្រាស់នូវពូជស្រូវចំនួន ១០ ពូជ ក្នុងចំណោមពូជស្រូវចំនួន ៣៨ ពូជ ដែលវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាបានបញ្ចេញជូនកសិករប្រើប្រាស់នាពេលកន្លងមកនេះ។

លទ្ធផលទាំងអស់នេះ បានបញ្ជាក់យ៉ាងច្បាស់ អំពីការទទួលស្គាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាពិសេសរបស់ **រាជរដ្ឋាភិបាល** លើសមិទ្ធផលនៃកិច្ចស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មនៃអង្គភាពជំនាញរបស់ខ្លួន ព្រមទាំងការគាំទ្រ និងចូលរួមក្នុងកិច្ចអភិវឌ្ឍន៍ផលិតកម្មដំណាំស្រូវនៅកម្ពុជាពីសំណាក់ដៃគូរអភិវឌ្ឍន៍នានា ជាពិសេស អូសអេដ (AusAID) វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលនានា។

អនុវត្តតាមតួនាទី និងដើម្បីឲ្យកសិករ ព្រមទាំងអ្នកពាក់ព័ន្ធកាន់តែងាយជ្រើសរើសពូជស្រូវ និងប្រើប្រាស់ជីឲ្យបានត្រឹមត្រូវតាមពេលវេលា និងប្រភេទដីស្រែរបស់ខ្លួន វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានរៀបចំកម្រងឯកសារនេះឡើង។ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះAusAID ដែលបានឧបត្ថម្ភថវិកាតាមរយៈ CAVAC និង ACIAR សម្រាប់ការបោះពុម្ពកម្រងឯកសារនេះ ចែកចាយជូនដល់អ្នកពាក់ព័ន្ធទាំងអស់។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១

បណ្ឌិត អ៊ុក ម៉ាការា

នាយក វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

Cambodian Agricultural Research and Development Institute (CARDI)

# មាតិកា


| | ទំព័រ |
|---|---|
| ចំណាត់ថ្នាក់ស្ថានភាពដីស្រែក្នុងប្រទេសកម្ពុជា......................................... | ១ |
| វិធីសាស្ត្រសាមញ្ញសម្រាប់កសិករធ្វើការកំណត់ក្រុមដីស្រែរបស់ខ្លួន............ | ៤ |
| ពូជស្រូវ "ជលសារ"...................................................................................... | ៨ |
| ពូជស្រូវ "អ៊ីអ៊ែរ៦៦"................................................................................... | ៩ |
| ពូជស្រូវ "សែនពិដោរ"................................................................................ | ១០ |
| ពូជស្រូវ "ផ្ការំដួល"..................................................................................... | ១១ |
| ពូជស្រូវ "ផ្ការំដេង"..................................................................................... | ១២ |
| ពូជស្រូវ "ផ្ការមៀត"................................................................................... | ១៣ |
| ពូជស្រូវ "ផ្កាច័ន្ទសែនសរ"......................................................................... | ១៤ |
| ពូជស្រូវ "រាំងជ័យ"...................................................................................... | ១៥ |
| ពូជស្រូវ "ខា៤"............................................................................................ | ១៦ |
| ពូជស្រូវ "ខា៦"............................................................................................ | ១៧ |
| វិធីសាស្ត្រសាមញ្ញសម្រាប់កសិករធ្វើការសម្រិតសម្រាំងគ្រាប់ពូជ................ | ១៨ |


Cambodian Agricultural Research and Development Institute (CARDI)

# កាឌី:　ចំណាត់ថ្នាក់ស្ថានភាពដីស្រែក្នុងប្រទេសកម្ពុជា

ការស្គាល់ឲ្យបានច្បាស់អំពីស្ថានភាពដីស្រែ ជួយឲ្យកសិករជ្រើសរើសប្រភេទពូជស្រូវយកមកដាំដុះបានត្រឹមត្រូវ និងទទួលបានទិន្នផលខ្ពស់។ តាមរយៈស្ថានភាពដីជម្រាល របបទឹកស្រោចស្រព និងជម្រៅទឹកដក់ក្នុងស្រែ ដីស្រែក្នុងប្រទេសកម្ពុជា ត្រូវបានបែងចែកជា ៤ ប្រភេទសំខាន់ៗ (រូបភាពទី ១) ដូចខាងក្រោម ៖



រូបភាពទី ១. ការបែងចែកដីស្រែតាមស្ថានភាពដី និងទឹក

## ១. ស្រែខ្ពង់រាប


ស្រូវស្រាល

គឺសំដៅដល់ដីស្រែណា ដែលមានសណ្ឋានជម្រាលខ្លាំង និងមធ្យមហើយដែលមិនដក់ទឹក និងមិនមានស្រែទាប់បាតនង្គ័ល។ ដំណាំស្រូវដែលដាំដុះនៅក្នុងក្សេត្របរិស្ថាននេះគឺជាស្រូវចម្ការ ដែលមានប្រព័ន្ធឬសចាក់ជ្រៅទៅក្នុងដីដើម្បីស្រូបយកទឹក និងសារធាតុចិញ្ចឹម។

## ២. ស្រែទំនាបរំពឹងទឹកភ្លៀង


ស្រូវកណ្ដាល

គឺសំដៅដល់ដីស្រែណា ដែលមានសណ្ឋានជម្រាលខ្សោយ និងមានស្រទាប់បាតនង្គ័ល បណ្ដាលឲ្យមានដក់ទឹកជាប់ជាប្រចាំអាចរហូតដល់រយៈពេល ០១ ខែ ដែលជាទូទៅមានក្នុងខែ តុលា ដោយសារទឹកភ្លៀង របបទឹកទន្លេ និងបឹងធំៗ។ យោងតាមស្ថានភាពនេះ ស្រែដែលបិតក្នុងតំបន់ទំនាបរំពឹងទឹកភ្លៀងនេះ ត្រូវបានបែងចែកជាបួនប្រភេទទៀតគឺៈ


ស្រូវធ្ងន់

២.១. ***ស្រែលើ*** គឺសំដៅដល់ដីស្រែណា ដែលមានទឹកដក់ជម្រៅជាមធ្យមពី ៥ ទៅ ២០ ស.ម ក្នុងរដូវវស្សា ហើយស្រកអស់ពីក្នុងស្រែបន្ទាប់ពីរាំងភ្លៀងក្នុងរយៈពេលប្រហែល ១០ ថ្ងៃ។ តាមស្ថានភាពដី និងទឹកក្នុងស្រែលើនេះ ពូជស្រូវដែលសមស្របបំផុតនោះ គឺជាប្រភេទពូជស្រូវណា ដែលចេញផ្កាមុនពាក់កណ្ដាលខែ តុលា ឬទុំក្នុងកំឡុងពេលពីថ្ងៃទី ៥–១៥ ខែ វិច្ឆិកា។ ដូច្នេះ ពូជស្រូវស្រាលមិនប្រកាន់រដូវ ដែលមានអាយុកាលខ្លីជាង ១២០ ថ្ងៃ និងមានកម្ពស់ពី ៩០–១២០ ស.ម ដូចជាពូជស្រូវ **សែនពិដោរ ផលសារ** និង**អ៊ីអ៊ែរ៦៦** ជាដើម គឺសមស្របបំផុត។

Cambodian Agricultural Research and Development Institute (CARDI)

២.២. *ស្រែកណ្តាល* គឺសំដៅដល់ដីស្រែណា ដែលមានទឹកដក់ជម្រៅជាមធ្យមពី ៥ ទៅ ៣០ ស.ម ក្នុងរដូវវស្សា ហើយស្រកអស់ពីក្នុងស្រែបន្ទាប់ពីរាំងភ្លៀងក្នុងរយៈពេលប្រហែល ១៥ ទៅ ២០ ថ្ងៃ។ ស្រែប្រភេទនេះ សមស្របសម្រាប់ពូជស្រូវកណ្តាលប្រកាន់រដូវ ដែលចេញផ្កាក្នុងកំឡុងពេលពីថ្ងៃទី ១៥ ខែ តុលា ដល់ថ្ងៃទី ៧ ខែ វិច្ឆិកា ឬទុំក្នុងកំឡុងពេលពីថ្ងៃទី ១៥ ខែ វិច្ឆិកា ដល់ថ្ងៃទី ៧ ខែ ធ្នូ និងមានកម្ពស់មធ្យមចាប់ពី ១២០–១៥០ ស.ម ដូចជាពូជស្រូវ **ផ្ការំដួល ផ្ការមៀត ផ្ការំដេង និងផ្កាច័ន្ទសែនសរ** ជាដើម។

២.៣. *ស្រែក្រោម* គឺសំដៅដល់ដីស្រែណា ដែលមានទឹកដក់ជម្រៅជាមធ្យមពី ៥ ទៅ ៥០ ស.ម ក្នុងរដូវវស្សា ហើយស្រកអស់ពីក្នុងស្រែបន្ទាប់ពីរាំងភ្លៀងក្នុងរយៈពេលប្រហែលចាប់ពី ៣០ ថ្ងៃ។ ពូជស្រូវដែលសមស្របសម្រាប់ស្រែក្រោមនេះ ជាប្រភេទពូជស្រូវធ្ងន់ ដែលមានកម្ពស់ពី ១៣០–១៧០ ស.ម និងចេញផ្កាចាប់ពីថ្ងៃទី ៨ ខែ វិច្ឆិកា ដល់ថ្ងៃទី ១៥ ខែ ធ្នូ ដូចជាពូជស្រូវ **រាំងជ័យ ខា៤ និងខា៦** ជាដើម។

២.៤. *ស្រែដើមរដូវវស្សា* គឺសំដៅដល់ដីស្រែណា ដែលកសិករមានប្រភពទឹកស្រោចស្រពបានមកពីប្រឡាយ ឬស្រះ ឬទឹកក្រោមដីបន្ថែម នាដើមរដូវវស្សាសម្រាប់ធ្វើស្រែដើមរដូវម្តង រួចបន្ទាប់មកស្ទូងស្រូវវស្សាម្តងទៀត។ ជាទូទៅស្រែដើមរដូវវស្សានេះ អាចធ្វើបានតែនៅដីស្រែកណ្តាល និងដីស្រែក្រោមតែប៉ុណ្ណោះ ពីព្រោះស្ថានភាពជម្រៅទឹកក្នុងតំបន់ទាំងនេះអនុញ្ញាតឲ្យដាំដុះស្រូវកណ្តាល និងស្រូវធ្ងន់បន្តទៀតដោយមិនខ្វះខាតទឹកនាចុងរដូវ។ ពូជស្រូវដែលសមស្របបំផុតសម្រាប់ស្រែដើមរដូវវស្សា គឺពូជស្រូវស្រាលមិនប្រកាន់រដូវ មានអាយុកាលមិនលើសពី ១២០ ថ្ងៃ ដូចជាពូជស្រូវ **សែនពិដោរ ជលសារ និងអ៊ីអ៊ែរ៦៦** ជាដើម។

## ៣. ស្រែទឹកជ្រៅ

គឺសំដៅដល់ដីស្រែណា ដែលមានទឹកដក់ជម្រៅជាមធ្យមចាប់ពី ៥០ ស.ម (អាចរហូតដល់ជម្រៅ ៤ ម៉ែត្រ) ក្នុងរដូវវស្សា ហើយស្រកអស់ពីក្នុងស្រែបន្ទាប់ពីរាំងភ្លៀងក្នុងរយៈពេលចាប់ពី ៤០ ថ្ងៃ ឡើងទៅ។ ដីស្រែប្រភេទនេះ គឺសមស្របសម្រាប់ពូជស្រូវឡើងទឹក (ជម្រៅទឹករហូតដល់ ២,៥ ម៉ែត្រ) និងស្រូវវារ (ជម្រៅទឹកចាប់ពី ២,៥ ម៉ែត្រឡើងទៅ)។

## ៤. ស្រែប្រាំង

គឺជាដីស្រែ ដែលមានប្រភពទឹកស្រោចស្រពទាំងស្រុង ឬភាគច្រើនដោយមិនពឹងផ្អែកលើរបបទឹកភ្លៀងទាំងស្រុងឡើយ។ ពូជស្រូវសមស្របសម្រាប់ស្រែប្រាំងនេះ គឺជាប្រភេទពូជស្រូវស្រាលមិនប្រកាន់រដូវ ដូចជាពូជស្រូវ **សែនពិដោរ ជលសារ និងអ៊ីអ៊ែរ៦៦** ជាដើម។ យោងតាមស្ថានភាពទឹកស្រែដែលបិតក្នុងក្សេត្របរិស្ថានស្រែប្រាំងនេះត្រូវបានបែងចែកជាបីប្រភេទទៀតគឺ៖

Cambodian Agricultural Research and Development Institute (CARDI)

៤.១. *ស្រែស្រោចស្រព* គឺសំដៅដល់ស្រែណា ដែលកសិករដាំដុះដំណាំស្រូវនារដូវប្រាំងដោយប្រើប្រាស់ទឹកសម្រាប់ស្រោចស្រពពីប្រព័ន្ធស្រោចស្រព ឬប្រព័ន្ធប្រឡាយ ឬទឹកក្រោមដីចាប់ពីសាបរហូតដល់ទុំ។

៤.២. *ស្រែប្រដេញទឹក* គឺសំដៅដល់ស្រែនៅតាមមាត់បឹង ឬអាងទឹកធំៗណា ដែលកសិករដាំដុះដំណាំស្រូវប្រដេញតាមទឹកស្រកនារដូវប្រាំង ដោយប្រើប្រាស់ទឹកបានមកពីប្រភពផ្សេងៗទៀតស្រោចស្រពបន្ថែមរហូតដល់ទុំ។

៤.៣. *ស្រែមុនទឹកចូល* គឺសំដៅដល់ស្រែនៅតាមមាត់បឹង ឬអាងទឹកធំៗណា ដែលកសិករដាំដុះដំណាំស្រូវនៅពេលណាដើម្បីឲ្យប្រមូលផលបានមុនទឹកចូល ដោយប្រើប្រាស់ទឹកបានមកពីប្រភពផ្សេងៗសម្រាប់ស្រោចស្រពនាដើមរដូវ និងទឹកភ្លៀងបន្ថែមរហូតដល់ទុំ។





Cambodian Agricultural Research and Development Institute
(CARDI)

# កាឡឺ: វិធីសាស្រ្តសាមញ្ញសម្រាប់កសិករធ្វើការកំណត់ក្រុមដីស្រែរបស់ខ្លួន

**ការ**ស្គាល់អំពីក្រុមដីស្រែរបស់ខ្លួន ជួយឲ្យកសិករប្រើប្រាស់ជីគីមីបានត្រឹមត្រូវ ដើម្បីបង្កើននូវផលស្រូវនិងប្រាក់ចំណូល ព្រមទាំងរក្សាបាននូវលំនឹងជីជាតិដី និងបរិស្ថាន។ ដើម្បីស្គាល់អំពីក្រុមដីស្រែរបស់ខ្លួន កសិករគ្រាន់តែជីកដីក្នុងជម្រៅពី ៥០–៦០ ស.ម យ៉ាងហោចណាស់ចំនួន ១ រណ្តៅនៅកណ្តាលស្រែរបស់ខ្លួន រួចតម្រឹមមុខជីកឲ្យបានត្រង់ល្អ បន្ទាប់មកវាស់ស្រទាប់ជម្រៅដីដោយម៉ែត្រ ឬបន្ទាត់ទៅតាមលក្ខណៈផ្សេងៗ និងកំណត់ក្រុមដីដូចខាងក្រោម។

**១. ក្រុមដីព្រៃខ្មែរ:** ដីក្នុងជម្រៅពី ០–៦០ ស.ម មានលក្ខណៈជាដីខ្សាច់ម៉ដ្ឋ ឬខ្សាច់គ្រើម។ ដីក្រុមនេះ ជាដីល្បាប់ចាស់ឬដីទំនាបគ្របដណ្តប់លើផ្ទៃដីដាំដុះស្រូវទាំងមូលប្រមាណពី ១០ – ១២%។

**២. ក្រុមដីប្រទះឡាង:** ដីក្នុងជម្រៅពី ០–៣០ ស.ម មានលក្ខណៈជាដីខ្សាច់ម៉ដ្ឋ។ ដីក្រុមនេះ ជាដីល្បាប់ចាស់ ឬដីទំនាបគ្របដណ្តប់លើផ្ទៃដីដាំដុះស្រូវទាំងមូលប្រមាណពី ២៥–៣០%។

**៣. ក្រុមដីបាកាន:** ដីក្នុងជម្រៅពី ០–២០ ស.ម មានលក្ខណៈជាដីល្បាយ ឬដីឥដ្ឋ មានពណ៌ប្រផេះ ឬត្នោត មិនបែកក្រហែង តែមានស្នាមប្រេះរាក់ៗនៅផ្ទៃខាងលើ។ ដីក្រុមនេះ ជាដីល្បាប់ចាស់នៅតាមជម្រាលជាថ្នាក់ៗ និងគ្របដណ្តប់លើផ្ទៃដីដាំដុះស្រូវទាំងមូលប្រមាណ ១០–១៥%។

**៤.ក្រុមដីអូរ្សង:** ដីក្នុងជម្រៅពី ០–៤០ ស.ម មានលក្ខណៈជាដីល្បាយ ឬឥដ្ឋ មានពណ៌ប្រផេះទៅប្រផេះភ្លឺ មានស្នាមប្រេះរាក់ៗនៅផ្ទៃខាងលើ។ ស្រទាប់ខាងក្រោម ជាដីខ្សាច់កម្រាស់ពី ១០–២០ ស.ម។ ដីក្រុមនេះ ជាដីវាលល្បាប់ចាស់ និងគ្របដណ្តប់លើផ្ទៃដីដាំដុះស្រូវទាំងមូលពី ១–២%។

**៥.ក្រុមដីទួលសំរោង:** ដីក្នុងជម្រៅពី ០–៤០ ស.ម មានលក្ខណៈជាដីឥដ្ឋ ឬល្បាយ មានពណ៌ប្រផេះ ឬត្នោត និងបែកក្រហែងធំជ្រៅជាង ៤ ស.ម ពេលដីស្ងួត។ ដីក្រុមនេះ កើតនៅលើល្បាប់ជំនន់ចាស់ ឬល្បាប់សំណឹក និងគ្របដណ្តប់លើផ្ទៃដីដាំដុះស្រូវទាំងមូលប្រមាណ ៧–១០%។



១. ក្រុមដីព្រៃខ្មែរ



២. ក្រុមដីប្រទះឡាង



៣. ក្រុមដីបាកាន

Cambodian Agricultural Research and Development Institute (CARDI)

**៦.ក្រុមដីគោគត្រប់:** ដីក្នុងជម្រៅពី ០–២០ ស.ម មានលក្ខណៈជាដីល្បាយ ឬឥដ្ឋ មានពណ៌ប្រផេះក្រមៅ ឬត្នោតក្រមៅទៅខ្មៅ និងបែកក្រហែងតូចទៅមធ្យម រាក់ ឬជ្រៅជាង ៤ ស.ម ពេលដីស្ងួត។ ដីក្រុមនេះ កើតនៅលើល្បាប់ជំនន់ចាស់ និងគ្របដណ្តប់លើផ្ទៃដីដាំដុះស្រូវទាំងមូលពី ៧–១០%។



៤. ក្រុមដីអូរ្លង



៥. ក្រុមដីទួលសំរោង



៦. ក្រុមដីគោគត្រប់

ការកំណត់លក្ខណៈដី:

ក. ដីខ្សាច់: ពេលសើមអាចពូតជាដុំមូលបាន ហើយសាច់ដី មានសភាពគ្រើម និងមិនស្អិតទេ ដូច្នេះដុំមូលនេះមិនអាច នៅបានយូរឡើយ។ ដីខ្សាច់មិនអាចលុញបង្កើត ជារូបរាងផ្សេងៗបានទេ។




ខ. ដីល្បាយ: ពេលសើម អាចលុញ ជារាងផ្សេងៗ បាន ប៉ុន្តែវាមានស្នាមប្រេះ ឬបាក់ ហើយមានភាពស្អិតជាប់ដៃបន្តិចបន្តួច។

គ. ដីឥដ្ឋ: ពេលសើម អាចលុញទំហំតូច ឬធំ និងពត់ជារាងផ្សេងៗបានយ៉ាងស្រួល។ ដីមានសភាពស្អិតរមួតជាប់ដៃ និងរលើបពេលសើម ព្រមទាំងអាចមានកម្ទេចខ្សាច់ ២–៣ គ្រាប់ផងដែរ។

Cambodian Agricultural Research and Development Institute (CARDI)

**៧. ក្រុមដីក្រគរ:** ដីក្នុងជម្រៅពី ០–៣០ ស.ម មានលក្ខណៈជាដីល្បាយឥដ្ឋ ឬឥដ្ឋមានពណ៌ប្រផេះទៅពណ៌ត្នោត និងបែកក្រហែងតូចទៅមធ្យម តែមិនជ្រៅជាង ៥ ស.ម នៅពេលដីស្ងួត។ ដីស្រទាប់ក្រោមមានលក្ខណៈជាដីឥដ្ឋ។ ដីក្រុមនេះ ជាដីវាលទំនាប ដែលលិចទឹកជារឿយៗ និងគ្របដណ្តប់លើផ្ទៃដីប្រមាណ ១៥% នៃផ្ទៃដីដាំដុះស្រូវទាំងមូល។

**៨. ក្រុមដីក្បាលពោធិ:** ដីក្នុងជម្រៅពី ០–៥០ ស.ម មានលក្ខណៈជាដីឥដ្ឋ មានពណ៌ប្រផេះទៅខ្មៅ និងមានបែកក្រហែងធំៗនៅពេលដីស្ងួត។ ដីក្រុមនេះ កើតនៅលើបាតអាងធំៗនៃទំនាបលិចទឹករយៈពេលយ៉ាងតិច ៣ ខែ ជារៀងរាល់ឆ្នាំ និងមានល្បាប់ថ្មីមកចាក់បំពេញបន្ថែមដែលគ្របដណ្តប់លើផ្ទៃដីប្រមាណ ១៣% នៃផ្ទៃដីដាំដុះស្រូវទាំងមូល។

**៩. ក្រុមដីកំពង់សៀម:** ដីក្នុងជម្រៅពី ០–៣០ ស.ម មានលក្ខណៈជាដីឥដ្ឋ មានពណ៌ប្រផេះក្រមៅ ឬខ្មៅ ប្រេះក្រហែងជ្រៅ និងស្រទាប់ក្រោមជាដីឥដ្ឋពណ៌ប្រផេះទៅប្រផេះភ្លឺ។ អាចមានគ្រួសតូចៗពណ៌ខ្មៅ ឬត្នោត និងថ្មបាសាល់នៅក្នុងស្រទាប់ដីទាំងពីរ។ ដីក្រុមនេះកើតនៅលើទំនាបនៃតំបន់ខ្ពង់រាប ដែលមានប្រមាណ ៥% នៃផ្ទៃដីដាំដុះស្រូវទាំងមូល។

**១០. ក្រុមដីកៀនស្វាយ:** ដីក្នុងជម្រៅជ្រៅ មានលក្ខណៈជាដីល្បាយ ឬឥដ្ឋ មានពណ៌ត្នោតភ្លឺទៅត្នោត ប្រេះក្រហែងធំៗចំពោះដីឥដ្ឋ។ ដីក្រុមនេះ កើតនៅលើច្រាំងទន្លេ លើទំនាបជម្រាលពីច្រាំងទន្លេ និងមានផ្ទៃដីប្រមាណ ២% នៃផ្ទៃដីដាំដុះស្រូវទាំងមូល។



៧. ក្រុមដីក្រគរ ៨. ក្រុមដីក្បាលពោធិ ៩. ក្រុមដីកំពង់សៀម ១០. ក្រុមដីកៀនស្វាយ



Cambodian Agricultural Research and Development Institute (CARDI)

| ក្រុមដី | ស្រូវស្រាលមិនប្រកាន់រដូវ (ស្រូវប្រាំង និងស្រូវវស្សា) | | | | ស្រូវកណ្តាល និងស្រូវធ្ងន់ (ស្រូវវស្សា) | | | | |
|---|---|---|---|---|---|---|---|---|---|
| | បាចទ្រាប់បាតមុនស្ទូង ឬព្រោះ (គ.ក្រ/ហាត) | | | បំប៉ន (គ.ក្រ/ហាត) | បាចទ្រាប់បាតមុនស្ទូង ឬព្រោះ (គ.ក្រ/ហាត) | | | បំប៉នអ៊ុយរ៉េ(គ.ក្រ/ហាត) | |
| | អ៊ុយរ៉េ ៤៦-០-០ | ដេ អា ប៉េ ១៨-៤៦-០ | ប៉ូតាស្យូ ០-០-៦០ | អ៊ុយរ៉េ ៤៦-០-០ | អ៊ុយរ៉េ ៤៦-០-០ | ដេ អា ប៉េ ១៨-៤៦-០ | ប៉ូតាស្យូ ០-០-៦០ | លើកទី ១ | លើកទី ២ |
| ដីព្រៃខ្មែរ | ២០ | ២៥ | ៤០ | ២៥ | ១០ | ២០ | ៤០ | ២០ | ១០ |
| ដីប្រទះឡាង | ២៥ | ៤០ | ៤០ | ៤០ | ១០ | ៤០ | ២៥ | ២៥ | ២៥ |
| ដីបាកាន ឬអូរុង | ៤០ | ៦០ | ៤០ | ៤០ | ២៥ | ២៥ | ២៥ | ៤០ | ២៥ |
| ដីទួលសំរោង | ៤០ | ៤០ | ០ | ១០០ | ២៥ | ៤០ | ០ | ២៥ | ២៥ |
| ដីគោកត្រប់ | ៤០ | ៧៥ | ៤០ | ៧៥ | ១០ | ៤០ | ៤០ | ៤០ | ៣៥ |
| ដីកំពង់សៀម | ៤០ | ០ | ០ | ៤០ | ៣០ | ០ | ០ | ៤០ | ៣០ |
| ដីកៀនស្វាយ | ៦០ | ០ | ០ | ៦០ | ជាដីតាមមាត់ច្រាំងទន្លេ និងជម្រាលពីច្រាំងទន្លេសមស្របសម្រាប់ស្រូវស្រាល | | | | |
| ដីក្រគរ | ១០០ | ៤០ | ០ | ១០០ | ជាដីលិចទឹករយៈពេលយូរ ដែលកសិករធ្វើស្រូវឡើងទឹក ឬប្រដេញទឹក | | | | |
| ដីក្បាលពោធិ | ៨៥ | ០ | ០ | ៨៥ | | | | | |

១ ត្រូវអនុវត្តៈ ☺ត្រូវធ្វើស្មៅមុនបាចជីបំប៉ន

៣ មិនត្រូវអនុវត្តៈ ☹មិនត្រូវបាចជីពេលស្លឹកស្រូវសើម ☹មិនត្រូវបាចជីបំប៉នពេលស្រែមិនមានទឹក ឬទឹកច្រើន ☹មិនត្រូវបាចជីបំប៉នពេលមានវត្តមានមមាចត្នោត

# កាឌី:                ពូជស្រូវ "ជលសារ"

*ពូជស្រូវ ជលសារ* ជាពូជស្រូវស្រាលមិនប្រកាន់រដូវ ដែលបានបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាចុងឆ្នាំ ១៩៩៩។

**លក្ខណ:សំខាន់ៗ៖**

- អាយុកាល (ថ្ងៃ) : ព្រោះ=៩៥ ស្ទូង=១០៥
- កម្ពស់ដើម (សម) : ៧៥-៩៣
- ទិន្នផលមធ្យម (ត/ហាត): ៤,០
- ចំនួនដើមបែកផ្តល់ផល : ១០-១៤ ដើម
- ប្រវែងកួរ (សម) : ២០-២៧
- ទម្ងន់ ១០០ គ្រាប់ (ក្រ) : ៣,០
- ប្រវែងគ្រាប់អង្ករ (មម) : ៦,៨
- បន្ទារគ្រាប់អង្ករ (មម) : ១,៩
- សណ្ឋានគ្រាប់អង្ករ : វល្វេន
- ភាពសពោះរបស់គ្រាប់អង្ករ : តូច
- ភាពថ្លារបស់គ្រាប់អង្ករ : ថ្លា
- ក្លិន : មិនមាន
- ភាពធន់ទ្រាំនឹងមមាចត្នោត : មធ្យម
- ភាពធន់ទ្រាំនឹងរាំងស្ងួត : មិនធន់
- ភាពធន់ទ្រាំនឹងទឹកជំនន់ : មិនធន់
- ប្រភេទអង្ករនៅទីផ្សារ : លេខ ២

**តំបន់សមស្របសម្រាប់ការដាំដុះ៖**

*ពូជស្រូវ ជលសារ* ជាពូជសមស្របសម្រាប់ (១)ស្រែស្រោចស្រព (២)ស្រែដើមរដូវវស្សា (៣)ស្រែលើ នៃស្រែទំនាបរំពឹងទឹកភ្លៀង ដែលមានជម្រៅទឹកមិនជ្រៅជាង ២០ សម និង(៤) ស្រែប្រដេញទឹក ឬស្រែមុនទឹកចូល។











Cambodian Agricultural Research and Development Institute (CARDI)

# កាឡី: ពូជស្រូវ "អ៊ីអ៊ែរ៦៦"

*ពូជស្រូវ អ៊ីអ៊ែរ៦៦* ជាពូជស្រូវស្រាលមិនប្រកាន់រដូវ ដែលបានបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងឆ្នាំ ១៩៩០។

- អាយុកាល (ថ្ងៃ) : ព្រោះ=១០៥ ស្ទូង=១១៥
- កម្ពស់ដើម (សម) : ៨០-១១៨
- ទិន្នផលមធ្យម (ត/ហាត): ៤,០
- ចំនួនដើមបែកផ្តល់ផល : ១២-១៨ដើម
- ប្រវែងកួរ (សម) : ២៥-២៦
- ទម្ងន់ ១០០ គ្រាប់ (ក្រ) : ២,២
- ប្រវែងគ្រាប់អង្ករ (មម) : ៧,២
- បន្ទារគ្រាប់អង្ករ (មម) : ២,០
- សណ្ឋានគ្រាប់អង្ករ : វល្វេន
- ភាពសពោះរបស់គ្រាប់អង្ករ : តូច
- ភាពថ្លារបស់គ្រាប់អង្ករ : ថ្លា
- ក្លិន : មិនមាន
- ភាពធន់ទ្រាំនឹងមមាចត្នោត : មិនធន់
- ភាពធន់ទ្រាំនឹងរាំងស្ងួត : មិនធន់
- ភាពធន់ទ្រាំនឹងទឹកជំនន់ : មិនធន់
- ប្រភេទអង្ករនៅទីផ្សារ : លេខ ២

**តំបន់សមស្របសម្រាប់ការដាំដុះ៖**

*ពូជស្រូវ អ៊ីអ៊ែរ៦៦* ជាពូជសមស្របសម្រាប់ (១)ស្រែស្រោចស្រព (២)ស្រែដើមរដូវវស្សា (៣)ស្រែលើ នៃស្រែទំនាបរំពឹងទឹកភ្លៀង ដែលមានជម្រៅទឹកមិនជ្រៅជាង ២០ សម និង(៤) ស្រែប្រដេញទឹក ឬស្រែមុនទឹកចូល។








Cambodian Agricultural Research and Development Institute (CARDI)

# កាឌី:                ពូជស្រូវ "សែនពិដោរ"

*ពូជស្រូវ សែនពិដោរ* ជាពូជស្រូវស្រាលមិនប្រកាន់រដូវ និងក្រអូប ដែលបានបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាដើមឆ្នាំ ២០០២។

- អាយុកាល (ថ្ងៃ) : ព្រោះ=១១០ ស្ទូង=១២០
- កម្ពស់ដើម (សម) : ៩៥-១១០
- ទិន្នផលមធ្យម (ត/ហាត): ៣,៥
- ចំនួនដើមបែកផ្តល់ផល: ៥-២០ ដើម
- ប្រវែងកួរ (សម) : ២០-៣០
- ទម្ងន់ ១០០ គ្រាប់ (ក្រ) : ២,២
- ប្រវែងគ្រាប់អង្ករ (មម) : ៧,០
- បន្ទារគ្រាប់អង្ករ (មម) : ២,០
- សណ្ឋានគ្រាប់អង្ករ : វល្វេន
- ភាពសពោះរបស់គ្រាប់អង្ករ : តូច
- ភាពថ្លារបស់គ្រាប់អង្ករ : ថ្លា
- ក្លិន : ក្រអូប
- ភាពធន់ទ្រាំនឹងមមាចត្នោត : មិនធន់
- ភាពធន់ទ្រាំនឹងរាំងស្ងួត : មិនធន់
- ភាពធន់ទ្រាំនឹងទឹកជំនន់ : មិនធន់
- ប្រភេទអង្ករនៅទីផ្សារ : ប្រណីត

**តំបន់សមស្របសម្រាប់ការដាំដុះ៖**

*ពូជស្រូវ សែនពិដោរ* ជាពូជសមស្របសម្រាប់ (១)ស្រែស្រោចស្រព (២)ស្រែដើមរដូវវស្សា (៣)ស្រែលើនៃស្រែទំនាបរំពឹងទឹកភ្លៀង ដែលមានជម្រៅទឹកមិនជ្រៅជាង ២០ សម និង (៤)ស្រែប្រដេញទឹក ឬស្រែមុនទឹកចូល។






Cambodian Agricultural Research and Development Institute (CARDI)

# កាឡ៊ី:                    ពូជស្រូវ "ផ្ការំដួល"

*ពូជស្រូវ ផ្ការំដួល* ជាពូជស្រូវកណ្តាលប្រកាន់រដូវមធ្យម និងក្រអូប ដែលបានបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនាចុងឆ្នាំ ១៩៩៩។

**លក្ខណ:សំខាន់ៗ៖**

- ពេលវេលាចេញផ្កា : ១០-២៥ ខែ តុលា
- កម្ពស់ដើម (សម) : ១១០-១៧០
- ទិន្នផលមធ្យម (ត/ហាត) : ៣,៥
- ចំនួនដើមបែកផ្តល់ផល : ៥-១០ ដើម
- ប្រវែងកួរ (សម) : ១៨-២៨
- ទម្ងន់ ១០០ គ្រាប់ (ក្រ) : ៣,០
- ប្រវែងគ្រាប់អង្ករ (មម) : ៧,៥
- បន្ទារគ្រាប់អង្ករ (មម) : ២,១
- សណ្ឋានគ្រាប់អង្ករ : រលូន
- ភាពសពោះរបស់គ្រាប់អង្ករ : តូច
- ភាពថ្លារបស់គ្រាប់អង្ករ : ថ្លា
- ក្លិន : ក្រអូប
- ភាពធន់ទ្រាំនឹងមមាចត្នោត : មិនធន់
- ភាពធន់ទ្រាំនឹងរាំងស្ងួត : មិនធន់
- ភាពធន់ទ្រាំនឹងទឹកជំនន់ : ធន់បាន ១៣ ថ្ងៃ
- ប្រភេទអង្ករនៅទីផ្សារ : ប្រណីត

**តំបន់សមស្របសម្រាប់ការដាំដុះ៖**

*ពូជស្រូវ ផ្ការំដួល* ជាពូជដុះលូតលាស់សមស្របនៅតំបន់ស្រែកណ្តាល នៃក្បេត្របរិស្ថានទំនាបរំពឹងទឹកភ្លៀង ដែលមានជម្រៅទឹកជាមធ្យម ៣០ សម ក្នុងខែ តុលា។ ពូជនេះអាចដាំដុះបាននៅតំបន់ស្រែលើ នៃក្បេត្របរិស្ថានស្រែទំនាបរំពឹងទឹកភ្លៀង ល្គឹកណាមានប្រភពទឹកសម្រាប់ស្រោចស្រពបន្ថែមនាចុងរដូវ។

| សាប ឬព្រោះ | ចេញផ្កា | បំប៉នអាសូតលើកទី១ | បំប៉នអាសូតលើកទី២ |
|---|---|---|---|
| ១-៣០ មិថុនា | ៥-១០ តុលា | ៣០ ថ្ងៃ បន្ទាប់ពីស្ទូង | ៥-១០ កញ្ញា |
| ១-១៥ កក្កដា | ១០-១៥ តុលា | ៣០-៦០ ថ្ងៃ បន្ទាប់ពីព្រោះ | ១០-១៥ កញ្ញា |
| ១៥-៣១ កក្កដា | ១៥-២៥ តុលា | | ១៥-២០ កញ្ញា |







Cambodian Agricultural Research and Development Institute (CARDI)

# កាឡី:                ពូជស្រូវ "ផ្ការំដេង"

*ពូជស្រូវ ផ្ការំដេង* ជាពូជស្រូវកណ្តាលប្រកាន់រដូវមធ្យម និងក្រអូប ដែលបានបញ្ចេញនិងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងឆ្នាំ ២០០៧។

- ពេលវេលាចេញផ្កា : ៥-២៥ ខែ តុលា
- កម្ពស់ដើម (សម) : ៨០-១៧៥
- ទិន្នផលមធ្យម (ត/ហាត) : ៣,៥
- ចំនួនដើមបែកផ្តល់ផល : ៨-២០ ដើម
- ប្រវែងកួរ (សម) : ២០-៣០
- ទម្ងន់ ១០០ គ្រាប់ (ក្រ) : ២,៩
- ប្រវែងគ្រាប់អង្ករ (មម) : ៧,២
- បន្ទារគ្រាប់អង្ករ (មម) : ២,២
- សណ្ឋានគ្រាប់អង្ករ : វល្វេន
- ភាពសពោះរបស់គ្រាប់អង្ករ : តូច
- ភាពថ្លារបស់គ្រាប់អង្ករ : ថ្លា
- ក្លិន : ក្រអូប
- ភាពធន់ទ្រាំនឹងមមាចត្នោត : មិនធន់
- ភាពធន់ទ្រាំនឹងរាំងស្ងួត : មិនធន់
- ភាពធន់ទ្រាំនឹងទឹកជំនន់ : ធន់បាន ១៣ ថ្ងៃ
- ប្រភេទអង្ករនៅទីផ្សារ : ប្រណីត

**តំបន់សមស្របសម្រាប់ការដាំដុះ៖**

*ពូជស្រូវ ផ្ការំដេង* ជាពូជដុះលូតលាស់សមស្របនៅតំបន់ស្រែកណ្តាល នៃស្រែទំនាបរំពឹងទឹកភ្លៀង ដែលមានជម្រៅទឹកជាមធ្យម ៣០ សម ក្នុងខែ តុលា។ ពូជនេះអាចដាំដុះបាននៅតំបន់ស្រែលើ នៃគេ្យត្របរិស្ថានស្រែទំនាបរំពឹងទឹកភ្លៀង ល្អិកណាមានប្រភពទឹកសម្រាប់ស្រោចស្រពបន្ថែមនាចុងរដូវ។

| សាប ឬព្រោះ | ចេញផ្កា | បំប៉នអាសូតលើកទី១ | បំប៉នអាសូតលើកទី២ |
|---|---|---|---|
| ១-៣០ មិថុនា | ៥-១០ តុលា | ៣០ ថ្ងៃ បន្ទាប់ពីស្ទូង | ៥-១០ កញ្ញា |
| ១-១៥ កក្កដា | ១០-១៥ តុលា | ៣០-៦០ ថ្ងៃ បន្ទាប់ពីព្រោះ | ១០-១៥ កញ្ញា |
| ១៥-៣១ កក្កដា | ១៥-២៥ តុលា | | ១៥-២០ កញ្ញា |








Cambodian Agricultural Research and Development Institute (CARDI)

# កាឌី: ពូជស្រូវ "ផ្ការមៀត"

*ពូជស្រូវ ផ្ការមៀត* ជាពូជស្រូវកណ្តាលប្រកាន់រដូវមធ្យម និងក្រអូប ដែលបានបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាឆ្នាំ ២០០៧។

**លក្ខណ:សំខាន់ៗ៖**

- ពេលវេលាចេញផ្កា : ៥-២៥ ខែ តុលា
- កម្ពស់ដើម (សម) : ១០០-១៥០
- ទិន្នផលមធ្យម (ត/ហត) : ៣,៥
- ចំនួនដើមបែកផ្តល់ផល : ៨-២០ ដើម
- ប្រវែងកួរ (សម) : ២០-៣០
- ទម្ងន់ ១០០ គ្រាប់ (ក្រ) : ២,៩
- ប្រវែងគ្រាប់អង្ករ (មម) : ៧,១
- បន្ទារគ្រាប់អង្ករ (មម) : ២,០
- សណ្ឋានគ្រាប់អង្ករ : វល្វេន
- ភាពសពោះរបស់គ្រាប់អង្ករ : តូច
- ភាពថ្លារបស់គ្រាប់អង្ករ : ថ្លា
- ក្លិន : ក្រអូប
- ភាពធន់ទ្រាំនឹងមមាចត្នោត : មិនធន់
- ភាពធន់ទ្រាំនឹងរាំងស្ងួត : មិនធន់
- ភាពធន់ទ្រាំនឹងទឹកជំនន់ : ធន់មធ្យម
- ប្រភេទអង្ករនៅទីផ្សារ : ប្រណីត

**តំបន់សមស្របសម្រាប់ការដាំដុះ៖**

*ពូជស្រូវ ផ្ការមៀត* ជាពូជដុះលូតលាស់សមស្របនៅតំបន់ស្រែកណ្តាល នៃស្រែទំនាបរំពឹងទឹកភ្លៀង ដែលមានជម្រៅទឹកជាមធ្យម ៣០ សម ក្នុងខែ តុលា។ ពូជនេះ អាចដាំដុះបាននៅតំបន់ស្រែលើ នៃកេ្សត្របរិស្ថានស្រែទំនាបរំពឹងទឹកភ្លៀង ល្គឹកណាមានប្រភពទឹកសម្រាប់ស្រោចស្រពបន្ថែមនាចុងរដូវ។

| សាប ឬព្រោះ | ចេញផ្កា | បំប៉នអាសូតលើកទី១ | បំប៉នអាសូតលើកទី២ |
|---|---|---|---|
| ១–៣០ មិថុនា | ៥–១០ តុលា | ៣០ ថ្ងៃ បន្ទាប់ពីស្ទូង | ៥–១០ កញ្ញា |
| ១–១៥ កក្កដា | ១០–១៥ តុលា | ៣០–៦០ ថ្ងៃ បន្ទាប់ពីព្រោះ | ១០–១៥ កញ្ញា |
| ១៥–៣១ កក្កដា | ១៥–២៥ តុលា | | ១៥–២០ កញ្ញា |









Cambodian Agricultural Research and Development Institute (CARDI)

# កាឡឺ: ពូជស្រូវ "ផ្កាច័ន្ទសែនសរ"

*ពូជស្រូវ ផ្កាច័ន្ទសែនសរ* ជាពូជស្រូវកណ្តាលប្រកាន់រដូវ ដែលបានបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាឆ្នាំ ២០១០។

**លក្ខណ:សំខាន់ៗ៖**

- ពេលវេលាចេញផ្កា : ២៥ ខែ តុលា-៥ ខែ វិច្ឆិកា
- កម្ពស់ដើម (សម) : ១៥០-១៦០
- ទិន្នផលមធ្យម (ត/ហាត) : ៣,៥
- ចំនួនដើមបែកផ្តល់ផល : ៧-១០ ដើម
- ប្រវែងកួរ (សម) : ២៥-២៨
- ទម្ងន់ ១០០ គ្រាប់ (ក្រ) : ២,៤
- ប្រវែងគ្រាប់អង្ករ (មម) : ៧,២
- បន្ទារគ្រាប់អង្ករ (មម) : ២,០
- សណ្ឋានគ្រាប់អង្ករ : វល្វន
- ភាពសពោះរបស់គ្រាប់អង្ករ : តូច
- ភាពថ្លារបស់គ្រាប់អង្ករ : ថ្លា
- ក្លិន : ក្រអូប
- ភាពធន់ទ្រាំនឹងមមាចត្នោត : មិនធន់
- ភាពធន់ទ្រាំនឹងរាំងស្ងួត : មិនទាន់ដឹង
- ភាពធន់ទ្រាំនឹងទឹកជំនន់ : ៧ ថ្ងៃ
- ប្រភេទអង្ករនៅទីផ្សារ : លេខ ១

**តំបន់សមស្របសម្រាប់ការដាំដុះ៖**

*ពូជស្រូវផ្កាច័ន្ទសែនសរ* ជាពូជដុះលូតលាស់សមស្របនៅតំបន់ស្រែកណ្តាល នៃស្រែទំនាបរំពឹងទឹកភ្លៀង ដែលមានជម្រៅទឹកជាមធ្យម ៣០ សម ក្នុងខែ តុលា។

| សាប ឬព្រោះ | ចេញផ្កា | បំប៉នអាសូតលើកទី១ | បំប៉នអាសូតលើកទី២ |
|---|---|---|---|
| ១–៣០ មិថុនា | ២៥–៣០ តុលា | ៣០ ថ្ងៃ បន្ទាប់ពីស្ទូង | ២០–២៥ កញ្ញា |
| ១–៣១ កក្កដា | ១–៥ វិច្ឆិកា | ៣០–៦០ ថ្ងៃ បន្ទាប់ពីព្រោះ | ២៥–៣០ កញ្ញា |








Cambodian Agricultural Research and Development Institute (CARDI)

# កាឡី:                    ពូជស្រូវ "រាំងជ័យ"

*ពូជស្រូវ រាំងជ័យ* ជាពូជស្រូវធ្ងន់ប្រកាន់រដូវ ដែលបានបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាចុងឆ្នាំ ១៩៩៩។

**លក្ខណៈសំខាន់ៗ៖**

- ពេលវេលាចេញផ្កា : ៥-១២ ខែ វិច្ឆិកា
- កម្ពស់ដើម (សម) : ១០៥-១៧០
- ទិន្នផលមធ្យម (ត/ហាត) : ៣,៥
- ចំនួនដើមបែកផ្តល់ផល : ៥-១០ ដើម
- ប្រវែងកួរ (សម) : ១៦-៣០
- ទម្ងន់ ១០០ គ្រាប់ (ក្រ) : ២,០
- ប្រវែងគ្រាប់អង្ករ (មម) : ៦,៥
- បន្ទារគ្រាប់អង្ករ (មម) : ២,១
- សណ្ឋានគ្រាប់អង្ករ : វល្លូន
- ភាពសពោះរបស់គ្រាប់អង្ករ : តូច
- ភាពថ្លារបស់គ្រាប់អង្ករ : ថ្លា
- ក្លិន : មិនមាន
- ភាពធន់ទ្រាំនឹងមមាចត្នោត : មិនធន់
- ភាពធន់ទ្រាំនឹងរាំងស្ងួត : មិនធន់
- ភាពធន់ទ្រាំនឹងទឹកជំនន់ : ធន់បាន ៧ ថ្ងៃ
- ប្រភេទអង្ករនៅទីផ្សារ : លេខ ១

**តំបន់សមស្របសម្រាប់ការដាំដុះ៖**

*ពូជស្រូវ រាំងជ័យ* ជាពូជដុះលូតលាស់សមស្របនៅតំបន់ស្រែក្រោម នៃស្រែទំនាបរំពឹងទឹកភ្លៀង ដែលមានជម្រៅទឹកជាមធ្យម ៥០ សម ក្នុងខែ តុលា។

| សាប ឬព្រោះ | ចេញផ្កា | បំប៉នអាសូតលើកទី១ | បំប៉នអាសូតលើកទី២ |
|---|---|---|---|
| ១-៣០ មិថុនា | ៥-១០ វិច្ឆិកា | ៣០ ថ្ងៃ បន្ទាប់ពីស្ទូង | ១-៥ តុលា |
| ១-៣១ កក្កដា | ១០-១២ វិច្ឆិកា | ៣០-៦០ ថ្ងៃ បន្ទាប់ពីព្រោះ | ៦-១០ តុលា |








Cambodian Agricultural Research and Development Institute (CARDI)

# កាឌី:                ពូជស្រូវ "ខា៨"

*ពូជស្រូវ ខា៤* ជាពូជស្រូវធ្ងន់ប្រកាន់រដូវ ដែលបានបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាចុងឆ្នាំ ១៩៩៩។

**លក្ខណ:សំខាន់ៗ៖**

- ពេលវេលាចេញផ្កា : ៨-១៥ ខែ វិច្ឆិកា
- កម្ពស់ដើម (សម) : ១០៥-១៧០
- ទិន្នផលមធ្យម (ត/ហត) : ៣,០
- ចំនួនដើមបែកផ្តល់ផល : ៦-១០ ដើម
- ប្រវែងកួរ (សម) : ២២-២៥
- ទម្ងន់ ១០០ គ្រាប់ (ក្រ) : ២,២
- ប្រវែងគ្រាប់អង្ករ (មម) : ៦,៨
- បន្ទារគ្រាប់អង្ករ (មម) : ២,២
- សណ្ឋានគ្រាប់អង្ករ : វល្លមធ្យម
- ភាពសពោះរបស់គ្រាប់អង្ករ : តូច
- ភាពថ្លារបស់គ្រាប់អង្ករ : ថ្លា
- ក្លិន : មិនមាន
- ភាពធន់ទ្រាំនឹងមមាចត្នោត : មិនធន់
- ភាពធន់ទ្រាំនឹងរាំងស្ងួត : ធន់មធ្យម
- ភាពធន់ទ្រាំនឹងទឹកជំនន់ : ធន់បាន ១០ ថ្ងៃ
- ប្រភេទអង្ករនៅទីផ្សារ : លេខ ១

**តំបន់សមស្របសម្រាប់ការដាំដុះ៖**

*ពូជស្រូវ ខា៤* ជាពូជដុះលូតលាស់សមស្របនៅតំបន់ស្រែក្រោម នៃស្រែទំនាបរំពឹងទឹកភ្លៀង ដែលមានជម្រៅទឹកជាមធ្យម ៥០ សម ក្នុងខែ តុលា។

| សាប ឬព្រោះ | ចេញផ្កា | បំប៉នអាសូតលើកទី១ | បំប៉នអាសូតលើកទី២ |
|---|---|---|---|
| ១-៣០ មិថុនា | ៨-១២ វិច្ឆិកា | ៣០ ថ្ងៃ បន្ទាប់ពីស្ទូង | ៥-៨ តុលា |
| ១-៣១ កក្កដា | ១២-១៥ វិច្ឆិកា | ៣០-៦០ ថ្ងៃ បន្ទាប់ពីព្រោះ | ៩-១២ តុលា |






Cambodian Agricultural Research and Development Institute (CARDI)

# កាឌី:                    ពូជស្រូវ "ខា៦"

*ពូជស្រូវ ខា៦* ជាពូជស្រូវធ្ងន់ប្រកាន់រដូវ ដែលបានបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាចុងឆ្នាំ ១៩៩៩។

**លក្ខណៈសំខាន់ៗ៖**

- ពេលវេលាចេញផ្កា : ១០-១៨ ខែ វិច្ឆិកា
- កម្ពស់ដើម (សម) : ១៣០-១៤០
- ទិន្នផលមធ្យម (ត/ហត) : ៣,៥
- ចំនួនដើមបែកផ្តល់ផល : ៧-១០ ដើម
- ប្រវែងកួរ (សម) : ២១-២៥
- ទម្ងន់ ១០០ គ្រាប់ (ក្រ) : ២,២
- ប្រវែងគ្រាប់អង្ករ (មម) : ៦,៦
- បន្ទារគ្រាប់អង្ករ (មម) : ២,២
- សណ្ឋានគ្រាប់អង្ករ : រលូនមធ្យម
- ភាពសពោះរបស់គ្រាប់អង្ករ : មធ្យម
- ភាពថ្លារបស់គ្រាប់អង្ករ : ថ្លាបង្គួរ
- ក្លិន : មិនមាន
- ភាពធន់ទ្រាំនឹងមមាចត្នោត : ធន់មធ្យម
- ភាពធន់ទ្រាំនឹងរាំងស្ងួត : មិនធន់
- ភាពធន់ទ្រាំនឹងទឹកជំនន់ : ធន់បាន ១០ ថ្ងៃ
- ប្រភេទអង្ករនៅទីផ្សារ : លេខ ១

**តំបន់សមស្របសម្រាប់ការដាំដុះ៖**

*ពូជស្រូវ ខា៦* ជាពូជដុះលូតលាស់សមស្របនៅតំបន់ស្រែក្រោម នៃស្រែទំនាបរំពឹងទឹកភ្លៀង ដែលមានជម្រៅទឹកជាមធ្យម ៥០ សម ក្នុងខែ តុលា។

| សាប ឬព្រោះ | ចេញផ្កា | បំប៉នអាសូតលើកទី១ | បំប៉នអាសូតលើកទី២ |
|---|---|---|---|
| ១–៣០ មិថុនា | ១០–១៥ វិច្ឆិកា | ៣០ ថ្ងៃ បន្ទាប់ពីស្ទូង | ៥–១០ តុលា |
| ១–៣១ កក្កដា | ១៥–១៨ វិច្ឆិកា | ៣០–៦០ ថ្ងៃ បន្ទាប់ពីព្រោះ | ១១–១៥ តុលា |








Cambodian Agricultural Research and Development Institute (CARDI)

# កាឌី: វិធីសាស្ត្រសាមញ្ញសម្រាប់កសិករធ្វើការសម្រិតសម្រាំងគ្រាប់ពូជ

## គុណវិបត្តិនៃការប្រើប្រាស់គ្រាប់ពូជមិនសុទ្ធ៖

**ភា**ពសុទ្ធនៃគ្រាប់ពូជស្រូវ គឺជាកត្តាចាំបាច់បំផុត ដែលកសិករគ្រប់រូបត្រូវតែយកចិត្តទុកដាក់។ គ្រាប់ពូជមិនសុទ្ធបណ្តាលឲ្យ៖

- ☹ បាត់បង់ផលពី ១០% ទៅ ៣០%
- ☹ អង្ករកិនបានតិច និងបាក់ច្រើន
- ☹ អង្ករ និងស្រូវលក់បានក្នុងតម្លៃថោក
- ☹ បាយទន់ ក្លាយជារឹង បាយក្រអូបក្លាយជាមិនក្រអូប
- ☹ បាយឆ្អិនមិនស្មើ និងឆាប់ផ្អូម
- ☹ សំណាបដុះមកមិនបានស្មើ និងធំធាត់ល្អដូចៗគ្នាទេ







## តើយើងត្រូវសម្រិតសម្រាំងគ្រាប់ពូជស្រូវយ៉ាងដូចម្តេច?

**កសិករ** អាចចាប់ផ្តើម ធ្វើការសម្រិតសម្រាំង គ្រាប់ពូជស្រូវ របស់ខ្លួនឯងជាជំហានៗដូចខាងក្រោម៖

**ជំហានទី១៖** ត្រូវដឹងអំពីទំហំស្រែ និងបរិមាណគ្រាប់ពូជដែលត្រូវការ។ ឧទាហរណ៍ ស្រែទំហំ ១ ហិកតា និងត្រូវការគ្រាប់ពូជសម្រាប់ស្ទូង ២០–៣០ គ.ក្រ។

**ជំហានទី ២៖** កំណត់នូវទំហំកូនស្រែសម្រាប់សម្រិតសម្រាំងគ្រាប់ពូជ ដែលត្រូវការដោយជ្រើសរើសទីតាំងក្នុងស្រែកន្លែងណាដែលស្រូវដុះបានល្អស្មើជាងគេកន្លងមក រួចបោះបង្គោលចងខ្សែព័ទ្ធជុំវិញលើផ្ទៃដីដែលអាចប្រមូលផលបានស្មើ ឬច្រើនជាងបរិមាណគ្រាប់ពូជត្រូវការបន្តិចបន្តួច។ ឧទាហរណ៍ ផលស្រូវប្រមូលក្នុង ១ ហិកតា បាន ៣.០០០គ.ក្រ គឺក្នុង ១ អា បាន ៣០ គ.ក្រ ដូច្នេះកូនស្រែសម្រាប់សម្រិតសម្រាំងពូជ គឺត្រូវមានទំហំយ៉ាងតូចបំផុត ១ អា។

**ជំហានទី ៣៖** កំណត់នូវបរិមាណគ្រាប់ពូជសម្រាប់ស្ទូងក្នុងកូនស្រែសម្រិតសម្រាំងគ្រាប់ពូជ។ យកគ្រាប់ពូជរក្សាទុកសម្រាប់សាប ឬព្រោះមកអុំ រែង ស្ទែ រើសយកតែគ្រាប់ពូជណាមានទំហំ និងពណ៌ប្រហាក់ប្រហែលគ្នា ឲ្យបានគ្រប់បរិមាណត្រូវការ។ ឧទាហរណ៍ សម្រាប់ស្ទូងស្រែ ១ អា ត្រូវការគ្រាប់ពូជ ១ គ.ក្រ។

Cambodian Agricultural Research and Development Institute (CARDI)






**ជំហានទី៤៖**ជ្រើសរើសដីថ្នាលសំណាប ដែលនៅជិតប្រភពទឹកងាយទៅមើលថែទាំ និងឆ្ងាយពីពន្លឺភ្លើងដោយកំណត់ផ្ទៃថ្នាល ១០ម$^2$សម្រាប់គ្រាប់ពូជ១គ.ក្រ។ ត្រូវធ្វើដីឲ្យបានស្អាតល្អ កុំឲ្យមានស្មៅ និងជាពិសេសគ្រាប់ស្រូវជ្រុះពីរដូវមុនដុះលាយឡំ។ ចូរថែទាំសំណាបឲ្យបានល្អ។

**ជំហានទី ៥៖** ត្រូវធ្វើដីកូនស្រែសម្រាប់សម្រិតសម្រាំងគ្រាប់ពូជឲ្យបានស្អាតនិងរាបស្មើល្អ។ស្ទូងសំណាបជាជួរ ឬឲ្យបានរៀងជាជួរចំនួន ២–៣ ដើមក្នុង ១ គុម្ព។ ការស្ទូងជាជួរជាការសំខាន់ណាស់សម្រាប់ការងារសម្រិតសម្រាំងគ្រាប់ពូជស្រូវ។ ចូរដាក់ទឹក ធ្វើស្មៅ ដាក់ជីទ្រាប់បាត និងបំប៉ន ព្រមទាំងថែទាំឲ្យស្រូវដុះលូតលាស់បានល្អ និងបានផលច្រើន។

**ជំហានទី ៦៖** បន្ទាប់ពីសន្ទូងដុះលូតលាស់បានល្អមក ត្រូវដើរកាត់ ឬដកគុម្ពស្រូវណា ដែលមានលក្ខណៈខុសគេចោលយ៉ាងហោចណាស់ចំនួន ៣ ដំណាក់កាលដូចខាងក្រោម៖

*<u>ដំណាក់កាលទី១</u>*ត្រូវធ្វើនៅពេលស្រូវបែកគុម្ពបន្ទាប់ពីស្ទូងរួចបាន ២០–៣០ ថ្ងៃ ដោយត្រូវដើរដកគុម្ពស្រូវណា ដែលដុះខុសជួរ និងមានលក្ខណៈខុសគេចោល។

Cambodian Agricultural Research and Development Institute (CARDI)

*ដំណាក់កាលទី ២* ត្រូវធ្វើនៅពេលស្រូវហាលផ្កា។ គុម្ពស្រូវណាចេញផ្កាយឺត ឬលឿនជាងគេប្រហែល ៣–៥ ថ្ងៃ ទម្រង់ និងពណ៌ គ្រាប់ និងកួរស្រូវខុសគេ ត្រូវកាត់ចោលឲ្យដល់គល់។

*ដំណាក់កាលទី ៣* ត្រូវធ្វើនៅពេលស្រូវទុំស្លាបសេក ដោយកាត់គុម្ពស្រូវណាមានជំងឺ សណ្ឋានកួរព្រមទាំងគ្រាប់មានកន្ទុយពណ៌ ប្រវែង និងទំហំខុសគេចោល។




**ជំហ៊ានទី ៧៖** ត្រូវប្រមូលផលស្រូវនៅពេលគ្រាប់ទុំល្អ គឺនៅពេលដែលកួរស្រូវយ៉ាងហោចណាស់ ៩0% មានគ្រាប់ចាប់ពីពាក់កណ្តាលកួរខាងលើពណ៌លឿងទុំចាស់ និងគ្រាប់ពេញពាក់កណ្តាលកួរ ខាងក្រោមពណ៌លឿងទុំស្រាលហើយគ្រាប់ស្កុកពណ៌ស្លាបសេកចាស់។





**ជំហ៊ានទី ៨៖** ត្រូវបោក ឬបែនដាច់ដោយឡែកពីគេ និងដោយប្រយ័ត្នប្រយែងបំផុត ព្រមទាំងអុំ និងរោយសម្អាតឲ្យបានល្អ។



**ជំហ៊ានទី ៩៖** ហាលសម្ងួតគ្រាប់ពូជស្រូវនៅលើកន្ទេលសំណាញ់ មុង និងតង់កៅស៊ូក្នុងកម្រាស់គ្រាប់ស្រូវ ២-៣ ស.ម និងឧស្សាហ៍រីជាប្រចាំរហូតស្ងួតល្អ រួចអុំ និងរោយសម្អាតឲ្យបានស្អាតល្អ កុំឲ្យមានគ្រាប់ស្កៀត គ្រាប់ស្មៅ និងកំទេចកំទីផ្សេងៗនៅលាយឡំ។



**ជំហ៊ានទី ១០៖** គ្រាប់ពូជស្រូវ ត្រូវច្រកទុកនៅក្នុងថង់ប្លាស្ទិក ចងមាត់ឲ្យជិត កុំឲ្យមានខ្យល់ រួចដាក់ក្នុងបាវមួយជាន់ទៀត ហើយទុកដាក់ដាច់ដោយឡែកពីគ្រាប់ស្រូវចំណី នៅកន្លែងដែលស្ងួតល្អ និងគ្មានការបំផ្លាញពីសត្វកណ្តុរ មាន់ ទាជាដើម។ ត្រូវសរសេរឈ្មោះពូជ និងថ្ងៃខែច្រូតកាត់ ដាក់នៅលើបាវឲ្យបានត្រឹមត្រូវល្អ។






Cambodian Agricultural Research and Development Institute (CARDI)




ផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

National Road NO 3, Prateah Lang Commune, Dangkor District,

Phnom Penh, Kingdom of Cambodia.

ទូរស័ព្ទលេខ: +(៨៥៥) ២៣ ៦៣១៩ ៦៩៣-៤

Tel: +( 855 ) 23 6319 693-4

ប្រអប់សំបុត្រ ០១ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

P.O. Box  01, Phnom Penh, Kingdom of Cambodia,

E-mail: cardi@cardi.org.kh, Website: www.cardi.org.kh

Cambodian Agricultural Research and Development Institute (CARDI)